**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ** : ៤២ សជណ . ថក

# សេចក្តីថ្លែងការណ៍

## ស្តីពីគោលនយោបាយផ្តល់សម្បទានដីសង្គមកិច្ច ជូនអតីតកងកម្លាំងប្រដាប់អាវុធ និង គ្រួសារ

## I. សេចក្តីផ្តើម

ក្នុងមួយឆ្នាំៗ មានកងកម្លាំងប្រដាប់អាវុធដល់អាយុចូលនិវត្តន៍ ហើយកងកម្លាំងប្រដាប់អាវុធខ្លះបានបាត់បង់សមត្ថភាពការងារ ពិការ ទទួលមរណភាព និង ពលីជីវិត ដើម្បីបុព្វហេតុជាតិ ការពារ សន្តិភាព បូរណភាពទឹកដី និង អធិបតេយ្យភាពនៃព្រះរាជាណាចក្រកម្ពុជា ។ រាជរដ្ឋាភិបាលបានអនុវត្តគោលនយោបាយជាតិចំពោះកងកម្លាំងប្រដាប់អាវុធ និង គ្រួសារដោយការគោរពដឹងគុណចំពោះគុណូបការៈដ៏ថ្លៃថ្លា របស់បងប្អូនចំពោះជាតិមាតុភូមិ និង ប្រជាជន ជាមួយនឹងការយកចិត្តទុកដាក់ដោះស្រាយជីវភាពខាង សម្ភារៈ ថវិកាជាបន្តបន្ទាប់ រួមមានការបើកផ្តល់នូវរបបឧបត្ថម្ភផ្សេងៗ ព្រមទាំងផ្តល់កិត្តិយសការគោរព និងការថែរក្សាសេចក្តីថ្លៃថ្នូរ ជូនបងប្អូនស្របតាមស្ថានភាពនៃសេដ្ឋកិច្ចជាតិ ។ ជាក់ស្តែង រាជរដ្ឋាភិបាលបានអនុវត្តរួចមកហើយនូវវិធានការ និង គំនិតផ្តួចផ្តើមសម្បទានដីសង្គមកិច្ចជូនកងកម្លាំងប្រដាប់អាវុធ និងគ្រួសាររួមមានជាអាទិ៍ ៖

**ទី១.** ការផ្តល់សម្បទានដីសង្គមកិច្ចនៅក្នុងក្របខ័ណ្ឌនៃការអនុវត្តគម្រោងរំសាយកងទ័ព

**ទី២.** ការផ្តល់សម្បទានដីសង្គមកិច្ចសម្រាប់អភិវឌ្ឍន៍យោធិន

**ទី៣.** ការកាត់ផ្ទៃដីព្រៃឈើទំហំ ២.៥០៧ ហិកតាដើម្បីជូនខេត្តសៀមរាបចំនួន ១.៣១៧ ហិកតា សម្រាប់គោលដៅសម្បទានដីសង្គមកិច្ច និង ជូនក្រសួងការពារជាតិចំនួន ១.១៩០ ហិកតា សម្រាប់បែងចែកជូនគ្រួសារយុទ្ធជន តាមរយៈអនុក្រឹត្យលេខ ៣៣ អនក្រ.បក ចុះថ្ងៃទី ១១ ខែ មេសា ឆ្នាំ ២០០៧

**ទី៤.** ការរៀបចំបង្កើតភូមិដ្ឋាន សម្រាប់គ្រួសារយុទ្ធជនកំពុងបំពេញការងារសកម្ម យុទ្ធជនពលី មរណៈ និង ពិការ ដែលត្រូវបានដាក់ចេញ និង ជំរុញអនុវត្តដោយ **សម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី** នៅតាមតំបន់មួយចំនួន រួមមានការផ្តល់សម្បទានដីសង្គមកិច្ចសម្រាប់យោធិនពិការនៅតំបន់តាកែនកោះស្លា នៅខេត្តកំពតចំនួន ២៤០ គ្រួសារ លើផ្ទៃដី ១២០០ ហិកតា ជូនគ្រួសារយោធិននៅស្រុកសេសានខេត្តស្ទឹងត្រែង ចំនួន ១០០ គ្រួសារ លើផ្ទៃដី ១៧៣ ហិកតា ជូនគ្រួសារកងទ័ពនៅស្រុកជាំក្សាន្តខេត្តព្រះវិហារចំនួន ១៩១២ គ្រួសារ លើផ្ទៃដី ១៦៤០០ ហិកតា

**ទី៥.** ការកសាងលំនៅដ្ឋានជូនអតីតយុទ្ធជនមានស្នាដៃល្អឆ្នើមក្នុងចលនាប្រឡងប្រណាំង ៣ ល្អ នៅតាមសហគមន៍របស់សមាគមអតីតយុទ្ធជនកម្ពុជាក្រោមការដឹកនាំរបស់ **សម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី**

**ទី៦.** ការដាក់បញ្ចូលក្នុងគម្រោងវិនិយោគសាធារណៈ ៣ ឆ្នាំ រំកិល២០១០-២០១២ នូវគំម្រោងសាងសង់ផ្ទះ និង ភូមិអភិវឌ្ឍន៍អតីតយុទ្ធជននៅខេត្តពោធិ៍សាត់ បាត់ដំបង កំពង់ធំ និង កំពង់ចាម

**ទី៧.** ការរៀបចំបង្កើតភូមិដ្ឋានគ្រួសារយោធានៅតំបន់បណ្តោយភូមិភាគខាងជើង ដែលថ្មីៗនេះត្រូវបាន និង កំពុងអនុវត្តដោយគណៈកម្មាធិការអន្តរក្រសួង ជាអ្នកសម្របសម្រួលរៀបចំ និងអនុវត្តគម្រោងអភិវឌ្ឍន៍ នៅតាមបណ្តោយព្រំដែនទិសខាងលិច និង ខាងជើងនៃព្រះរាជាណាចក្រកម្ពុជា ។ល។

## II. គោលដៅខាងសង្គម - សេដ្ឋកិច្ចនៃការផ្តល់សម្បទានដីសង្គមកិច្ច ជូនកម្លាំងប្រដាប់អាវុធចូលនិវត្តន៍ ចូលបាត់បង់សមត្ថភាពការងារ ពិការ និង គ្រួសាររបស់កងកម្លាំងប្រដាប់អាវុធពលី និងមរណៈ

ក្រៅពីគោលការណ៍ពង្រឹង និង ពង្រីកសំណាញ់សុវត្ថិភាពសង្គមប្រកបដោយចិរភាព និង បម្រើឱ្យការដ្ឋានកំណែទម្រង់កងកម្លាំងប្រដាប់អាវុធតាម **យុទ្ធសាស្ត្រចតុកោណ - ដំណាក់កាលទី ២** ការផ្តល់សម្បទានដីសង្គមកិច្ចជូនកងកម្លាំងប្រដាប់អាវុធ ដែលចូលនិវត្តន៍ ចូលបាត់បង់សមត្ថភាពការងារ ពិការ និង គ្រួសាររបស់កងកម្លាំងប្រដាប់អាវុធ ដែលពលី និង មរណៈ នឹង នាំមកនូវបច្ច័យល្អជាគោលដៅសង្គម-សេដ្ឋកិច្ចថែមទៀត គឺ ៖

**ទី១.** ការរៀបចំផែនការបែងចែកកម្លាំងពលកម្មឡើងវិញ ដោយផ្ទេរកម្លាំងមិនបានចូលរួមដោយផ្ទាល់នៅក្នុងវិស័យផលិតកម្ម ឱ្យទៅជាកម្លាំងផលិតកម្មពិតៗ ដែលជាការផ្តល់ឱកាសដល់អតីតកងកម្លាំងប្រដាប់អាវុធ និង ក្រុមគ្រួសារ អាចមានធនធានដីធ្លី សម្រាប់ប្រកបរបរផ្គត់ផ្គង់ជីវភាពគ្រួសារផង និង អាចចូលរួមវិភាគ ទានប្រកបដោយផលិតភាពទៅក្នុងការអភិវឌ្ឍន៍ប្រទេសជាតិផង

**ទី២.** ការកាត់បន្ថយចំណាយលើផ្នែកយោធា និង សន្តិសុខជាតិបានមួយកម្រិត ហើយឆ្លុះបញ្ចាំងសារជាតិចំណាយពិតប្រាកដនៅក្នុងវិស័យបណ្តាញសុវត្ថិភាពសង្គម

**ទី៣.** ការធ្វើសមាហរណកងកម្លាំងប្រដាប់អាវុធ ដែលចូលនិវត្តន៍ ចូលបាត់បង់សមត្ថភាពការងារពិការ និង គ្រួសាររបស់កងកម្លាំងប្រដាប់អាវុធពលី និង មរណៈក្នុងសង្គមជាតិ ដើម្បីចូលរួមចំណែកកាត់បន្ថយភាពក្រីក្ររបស់ប្រជាជន។

## III. ***គោលការណ៍ផ្តល់សម្បទានដីសង្គមកិច្ចជូនកងកម្លាំងប្រដាប់អាវុធចូលនិវត្តន៍ ចូលបាត់បង់សមត្ថភាពការងារ ពិការ និង គ្រួសាររបស់កងកម្លាំងប្រដាប់អាវុធពលី និង មរណៈ***

ដើម្បីសម្រេចគោលដៅខាងសង្គម-សេដ្ឋកិច្ច ព្រមទាំងការពង្រឹង និង ពង្រីកសំណាញ់សុវត្ថិភាពសង្គមដូចគូសបញ្ជាក់ខាងលើ រាជរដ្ឋាភិបាលឈរលើគោលការណ៍ចម្បងៗមួយចំនួនដូចតទៅ ៖

**១. គោលការណ៍សមធម៌:** រាជរដ្ឋាភិបាលនិងរៀបចំជាអាទិភាពនៅក្នុងការរៀបចំគោលនយោបាយរបស់ខ្លួន ដោយកំណត់មុខសញ្ញានៃអ្នកដែលស័ក្តិសមត្រូវទទួលបាននូវសម្បទានដីសង្គមកិច្ច និង អាទិភាពព្រមទាំងលំដាប់លំដោយនៃការផ្តល់សម្បទានដីសង្គមកិច្ចនេះ ដោយច្បាស់លាស់ ។ រាជរដ្ឋាភិបាលមិនអាចផ្តល់សម្បទានដីសង្គមកិច្ចដោយឈរលើគោលការណ៍ ***សមភាព*** ជូនដល់គ្រប់គ្រួសារអតីតកងកម្លាំងប្រដាប់អាវុធនោះទេដោយសារមូលហេតុ ៖

- ធនធានហិរញ្ញវត្ថុរបស់រដ្ឋមានកម្រិត
- ការអនុវត្តគោលនយោបាយជាតិស្តីពីការគ្រប់គ្រងដីតាមគោលការណ៍ប្រសិទ្ធភាព
- ស្ថានភាពជីវភាពនៃអតីតកងកម្លាំងប្រដាប់អាវុធ និង គ្រួសាររបស់គេនីមួយៗមិនដូចគ្នាទាំងអស់ បានន័យថា មានអ្នកមានជីវភាពធូរធារមិនត្រូវការដី និង មានអ្នកក្រីក្រ ហើយត្រូវការដី
- សេចក្តីត្រូវការរបស់គ្រួសារនីមួយៗក៏មិនដូចគ្នាដែរ

**២.គោលការណ៍ប្រសិទ្ធភាពក្នុងការគ្រប់គ្រងដី:** ដី គឺជាធនធានដែលមានកំណត់ និង មិនងាយ នឹងពង្រីកបាន គឺជាធនធានធម្មជាតិសំខាន់ជាមូលដ្ឋាន ដែលអាចយកមកប្រើប្រាស់សម្រាប់អភិវឌ្ឍសង្គមសេដ្ឋកិច្ចដែលទាមទារឱ្យមានការគ្រប់គ្រងប្រកបដោយប្រសិទ្ធភាព និង វិចារណភាព ដើម្បីធានាដោះស្រាយប្រកបដោយចិរភាពនូវសេចក្តីត្រូវការរបស់ប្រទេសជាតិ និង ប្រជាជនរាប់ជំនាន់តទៅមុខទៀត ។ ក្នុងស្មារតីនេះក្នុងការផ្តល់សម្បទានដីសង្គមកិច្ចជូនដល់អតីតយុទ្ធជន និង ក្រុមគ្រួសារ រាជរដ្ឋាភិបាលនឹងផ្សារភ្ជាប់ទៅនឹងតម្រូវការចាំបាច់ក្នុងការពង្រឹងប្រសិទ្ធភាព និង ផលិតភាពក្នុងការគ្រប់គ្រងធនធានដីរបស់រដ្ឋក្នុងលក្ខណៈជាប្រព័ន្ធ ជាពិសេសក្នុងទិដ្ឋភាពគោលនយោបាយពាក់ព័ន្ធទៅនឹងការកំណត់ និង គ្រប់គ្រងធនធានដីបម្រុងរបស់រដ្ឋ ការកំណត់ និង បែងចែកឡើងវិញនូវប្រភេទដីគម្របព្រៃ និង ដីព្រៃរិចរិល ដែលអាចកាត់យកមកប្រើប្រាស់ សម្រាប់គោលដៅនៃសម្បទានដីសង្គមកិច្ច ការកាត់យកមកវិញនូវដីសម្បទានសេដ្ឋកិច្ចដែលមិនត្រូវបានប្រើប្រាស់ត្រឹមត្រូវតាមគោល

ដៅនៃកិច្ចសន្យា សម្រាប់គោលដៅនៃសម្បទានដីសង្គមកិច្ច និង ការពង្រឹងទំនាក់ទំនងរវាងសម្បទានដីសេដ្ឋកិច្ច និង សម្បទានដីសង្គមកិច្ច ដូចមានចែងនៅក្នុង **យុទ្ធសាស្ត្រចតុកោណ**

**៣. គោលការណ៍ប្រសិទ្ធភាពសេដ្ឋកិច្ចក្នុងការប្រើប្រាស់ដីសម្បទានសង្គមកិច្ច:** គោលដៅចម្បងមួយនៃការផ្តល់សម្បទានដីសង្គមកិច្ចជូនដល់អតីតកងកម្លាំងប្រដាប់អាវុធ និង គ្រួសារ គឺសំដៅបង្កើតឡើងនូវសំណាញ់សុវត្ថិភាពសង្គម សម្រាប់គ្រួសារអតីតកងកម្លាំងប្រដាប់អាវុធដែលទីទ័លក្រពិតប្រាកដ ដើម្បីសាងសង់លំនៅដ្ឋាន និង ប្រកបរបរកសិកម្មផ្សេងៗ ដែលជាការរួមចំណែកដល់ការលើកកម្ពស់កម្រិតជីវភាពរស់នៅរបស់អតីតកងកម្លាំងប្រដាប់អាវុធ និង គ្រួសារផង និង ជាការលើកកម្ពស់ផលិតភាព និង ពិធភាវូបនីយកម្មកសិកម្មក្នុងគោលដៅនៃការអភិវឌ្ឍសេដ្ឋកិច្ចនេះ រាជរដ្ឋាភិបាលមិនអនុញ្ញាតឱ្យមានការទទួលយកសម្បទានដីសង្គមកិច្ចពីរដ្ឋរួចហើយ រួចយកទៅរក្សាទុកលក់ចំណេញ ឬ យកទៅជួល ឬ ប្រវាស់ ឬ ព័ទ្ធរបងទុកចោលដោយមិនប្រើប្រាស់ជាដើមឡើយ

**៤. គោលការណ៍ធ្វើសមាហរណកម្មអតីតកងកម្លាំងប្រដាប់អាវុធចូលទៅក្នុងសង្គមជាតិ:**

គោលដៅដល់សំខាន់មួយ ក្នុងក្របខណ្ឌនៃកំណែទម្រង់កងកម្លាំងប្រដាប់អាវុធដែលចូលនិវត្តន៍ចូលបាត់បង់សមត្ថភាពការងារ ពិការ ពលី និង មរណៈ ចូលទៅក្នុងសង្គមជាតិ ដើម្បីឱ្យពួកគេអាចរស់នៅបានក្នុងជីវភាពជាជនស៊ីវិលនៅក្នុងភាពសុខដុមរមនាជាមួយនឹងគ្រួសារ និង សហគមន៍ ។ ដើម្បីសម្រេចគោលដៅនេះ រាជរដ្ឋាភិបាលនឹងមានវិធានការជាប្រព័ន្ធគ្រប់ជ្រុងជ្រោយ ដោយលើកផែនការរៀបចំភូមិដ្ឋាន សម្រាប់ការតាំងទីលំនៅ និង ការប្រកបរបរអាជីវកម្មនៅតាមទីតាំងដែលនឹងត្រូវបានផ្តល់ជាសម្បទានដីសង្គមកិច្ចក្នុងនោះមានការរួមបញ្ចូលនូវការរៀបចំបណ្តាញហេដ្ឋារចនាសម្ព័ន្ធសង្គម-សេដ្ឋកិច្ចជារូបវន្ត មានជាអាទិ៍: បណ្តាញផ្លូវគមនាគមន៍ ប្រព័ន្ធធារាសាស្ត្រ សាលារៀន មណ្ឌលសុខភាព វត្តអារាម ព្រមទាំងការផ្តល់ជំនួយឧបត្ថម្ភ សម្រាប់ការសាងសង់ទីលំនៅ និងសម្រាប់ការស្នាក់នៅក្នុងដំណាក់ការដំបូងតាមការចាំបាច់ និង ការផ្តល់សេវាសង្គមកិច្ចព្រមទាំងការបណ្តុះបណ្តាលផ្សេងៗសម្រាប់ការកសាងជីវភាពរស់នៅក្នុងរយៈពេលវែង។

## IV. ក្របខណ្ឌច្បាប់

ដើម្បីអនុវត្តគោលការណ៍នៃការផ្តល់សម្បទានដីសង្គមកិច្ច ជូន កងកម្លាំងប្រដាប់អាវុធចូលនិវត្តន៍ចូលបាត់បង់សមត្ថភាពការងារ ពិការ និង គ្រួសាររបស់កងកម្លាំងប្រដាប់អាវុធពលី និង មរណៈ រាជរដ្ឋាភិបាលនឹងអនុវត្តច្បាប់ លិខិតបទដ្ឋាន និង ឯកសារគោលនយោបាយដូចទៅ៖

- សេចក្តីប្រកាសរបស់រដ្ឋាភិបាល ចុះថ្ងៃទី ១៦ ខែ ឧសភា ឆ្នាំ ២០០១ ស្តីពីគោលនយោបាយដីធ្លី
- ច្បាប់ភូមិបាល ដែលត្រូវបានប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/ករម/០៨០១/១៤ ចុះថ្ងៃទី ៣០ ខែ សីហា ឆ្នាំ ២០០១

- ក្របខណ្ឌយុទ្ធសាស្ត្រ នៃគោលនយោបាយដីធ្លីរបស់រាជរដ្ឋាភិបាលចុះថ្ងៃទី ៦ ខែ កញ្ញា ឆ្នាំ ២០០២
- គោលនយោបាយស្តីពីសម្បទានដីសង្គមកិច្ច នៃព្រះរាជាណាចក្រកម្ពុជាចុះថ្ងៃទី ១៩ មីនា ឆ្នាំ២០០៣
- អនុក្រឹត្យលេខ ១៩ អនក្រ.បក ចុះថ្ងៃទី ១៩ មីនា ឆ្នាំ ២០០៣ ស្តីពីសម្បទានដីសង្គមកិច្ចនៃព្រះរាជាណាចក្រកម្ពុជា
- ប្រកាសលេខ ២០០ ដនស/ប្រ.ក ចុះថ្ងៃទី១៩ ខែវិច្ឆិកា ឆ្នាំ២០០៣ ស្តីពីគោលការណ៍ណែនាំអនុវត្តអនុក្រឹត្យស្តីពីសម្បទាន នៃព្រះរាជាណាចក្រកម្ពុជា
- សារាចរណែនាំលេខ ០៦ សរណន ចុះថ្ងៃទី ៨ ខែ វិច្ឆិកា ឆ្នាំ ២០០៧ ស្តីពីការអនុវត្តផែនការបែងចែកសម្បទានដីសង្គមកិច្ច
- សេចក្តីប្រកាសរបស់រាជរដ្ឋាភិបាល ចុះថ្ងៃទី ១ ខែ កក្កដា ឆ្នាំ ២០០៩ ស្តីពីគោលនយោបាយដីធ្លីដើម្បីឈានទៅការរៀបចំ គោលនយោបាយ ដីធ្លីជាតិដ៏ទូលំទូលាយ ។

## V. **វិធានការ និង យន្តការអនុវត្តជាក់ស្តែង**

ដើម្បីប្រែក្លាយសេចក្តីថ្លែងការណ៍នេះ ពីគោលនយោបាយផ្តល់សម្បទានដីសង្គមកិច្ចជូនកងកម្លាំងប្រដាប់អាវុធគ្រប់ប្រភេទ ដែលចូលនិវត្តន៍ ចូលបាត់បង់សមត្ថភាពការងារ ពិការ និង គ្រួសាររបស់កងកម្លាំងប្រដាប់អាវុធពលី និង មរណៈ រាជរដ្ឋាភិបាលសម្រេចដូចតទៅ៖

**ទី១.** ក្រសួងការពារជាតិ និង ក្រសួងមហាផ្ទៃ ត្រូវរៀបចំផែនការផ្ទេរក្របខណ្ឌកងកម្លាំងប្រដាប់អាវុធ ដែលត្រូវចូលនិវត្តន៍ ចូលបាត់បង់សមត្ថភាពការងារ ពិការ ពលី និង មរណៈ ឱ្យទៅស្ថិតក្រោមការគ្រប់គ្រងរបស់ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និង យុវនីតិសម្បទា ។ ក្នុងកិច្ចការនេះ ក្រសួងការពារជាតិ ក្រសួងមហាផ្ទៃ និង ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និង យុវនីតិសម្បទា ត្រូវរៀបចំប្រព័ន្ធទិន្នន័យ ដែលមានបញ្ជីឈ្មោះច្បាស់លាស់ទៅតាមអង្គភាពនីមួយៗ បង្កើតឱ្យមានយន្តការផ្ទៀងផ្ទាត់ និង ធ្វើបច្ចុប្បន្នភាពជាប្រចាំ ដោយសហការជិតស្និទ្ធជាមួយក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ដើម្បីពង្រឹងការគ្រប់គ្រងលើការផ្ទេរកងកម្លាំងប្រដាប់អាវុធ ដែលចូលនិវត្តន៍ ចូលបាត់បង់សមត្ថភាពការងារ ពិការ ពលី និង មរណៈនេះ។ ដោយឡែក ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ត្រូវរៀបចំផែនការថវិកាជូនក្រសួងការពារជាតិ សម្រាប់ការផ្ទេរយោធិនប្រភេទ ២ ជាដំណាក់ៗ ពីក្រសួងការពារជាតិឱ្យទៅស្ថិតនៅក្រោមការគ្រប់គ្រងរបស់ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និង យុវនីតិសម្បទា

**ទី២.** ស្របតាមផែនការនៃការផ្ទេរនេះ អ្នកដែលមិនទាន់ត្រូវបានផ្ទេរចេញពីជួរកងកម្លាំងប្រដាប់អាវុធនឹងបន្តទទួលបាននូវការយកចិត្តទុកដាក់ប្រកបដោយសមធម៌ ដូចជាកងកម្លាំងប្រដាប់អាវុធក្នុងជួរដទៃទៀតដែរ

**ទី៣.** អ្នកដែលនឹងត្រូវបានផ្ទេរចេញពីជួរកងកម្លាំងប្រដាប់អាវុធ ស្របតាមផែនការនេះ គឺនឹងត្រូវក្លាយទៅជាមុខសញ្ញានៃការកំណត់អត្តសញ្ញាណ សម្រាប់ការផ្តល់សម្បទាន ដីសង្គមកិច្ចជាអទិភាព មុនគេ ចំពោះអ្នកដែលត្រូវបានផ្ទេរចេញកន្លងមក គឺនឹងត្រូវស្ថិតនៅអាទិភាពបន្ទាប់នៃការកំណត់អត្តសញ្ញាណសម្រាប់ការផ្តល់សម្បទានដីសង្គមកិច្ច

**ទី៤.** បង្កើតគណៈកម្មាធិការអន្តរក្រសួងមួយធ្វើជាយន្តការ សម្រាប់កំណត់អត្តសញ្ញាណកងកម្លាំងប្រដាប់អាវុធចូលនិវត្តន៍ ចូលបាត់បង់សមត្ថភាពការងារ ពិការ និង គ្រួសារ យុទ្ធជនពលី មរណៈដែលត្រូវទទួលសម្បទានដីសង្គមកិច្ច ដែលមានសមាសភាពដូចតទៅ៖

| | |
|---|---|
| ១ . រដ្ឋមន្ត្រីក្រសួងសង្គមកិច្ច អតីតយុទ្ធជន និង យុវនីតិសម្បទា | ជាប្រធាន |
| ២ . រដ្ឋលេខាធិការក្រសួងការពារជាតិ | ជាអនុប្រធាន |
| ៣ . រដ្ឋលេខាធិការក្រសួងមហាផ្ទៃ | ជាអនុប្រធាន |
| ៤ . រដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ | ជាសមាជិក |
| ៥ . រដ្ឋលេខាធិការក្រសួងរៀបចំដែនដី នគរូបនីយកម្ម និង សំណង់ | ជាសមាជិក |
| ៦ . រដ្ឋលេខាធិការក្រសួងកិច្ចការនារី | ជាសមាជិក |
| ៧ . អភិបាល ឬ អភិបាលរងរាជធានី/ខេត្តដែលពាក់ព័ន្ធ | ជាសមាជិក |

គណៈកម្មាធិការនេះ មានភារកិច្ចកំណត់លក្ខណៈវិនិច្ឆ័យ អាទិភាពរៀបចំបញ្ជីឈ្មោះ និង ធ្វើបច្ចុប្បន្នភាពអតីតកងកម្លាំងប្រដាប់អាវុធ និង គ្រួសារដែលមានជីវភាពលំបាកក្រីក្រ ខ្វះទីលំនៅ ខ្វះដីប្រកបរបរកសិកម្មពិតប្រាកដ និង មានបំណងចង់ទៅរស់នៅលើដីសម្បទានដែលរដ្ឋនឹងផ្តល់ជូន

**ទី៥.** ក្រោយពីការកំណត់អត្តសញ្ញាណកងកម្លាំងប្រដាប់អាវុធ និង គ្រួសារ សម្រាប់ការផ្តល់សម្បទានដីសង្គមកិច្ចត្រូវបានធ្វើរួចហើយ គណៈកម្មាធិការនេះត្រូវបញ្ជូនឈ្មោះនោះ ទៅកាន់គណៈកម្មាធិការសម្បទានដីសង្គមកិច្ចថ្នាក់ជាតិ ដើម្បីចាត់ការបន្តតាមអាទិភាព តាមបណ្តោយរបស់ខ្លួននៅថ្នាក់ខេត្ត ក្រុង ស្រុក ខណ្ឌ និង ឃុំ សង្កាត់

**ទី៦.** ចំពោះយន្តការនៃការអនុវត្ត ដែលរួមបញ្ចូលតាំងពីការកំណត់ទីតាំងរហូតដល់ការបែងចែកសម្បទានដីសង្គមកិច្ច និង ការតាមដានក្រោយពីការផ្តល់ដីសម្បទានដីសង្គមកិច្ចរួច ។ល។ គឺជាយន្តការសម្បទានដីសង្គមកិច្ចរបស់រាជរដ្ឋាភិបាលដែលមានស្រាប់ កំណត់ដោយអនុក្រឹត្យលេខ ១៩ អនក្រ. បកចុះថ្ងៃទី ១៩ ខែ មិនា ឆ្នាំ ២០០៣ ។ យន្តការនេះ ដែលមានរដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគររូបនីយកម្ម និងសំណង់ជាប្រធានគណៈកម្មាធិការសម្បទានដីសង្គមកិច្ចថ្នាក់ជាតិ និង មានបណ្តោយរៀបចំតាំងពីថ្នាក់ជាតិដល់មូលដ្ឋានថ្នាក់ឃុំ សង្កាត់ និង មានក្របខណ្ឌនីតិវិធីគ្រប់ជ្រុងជ្រោយ ត្រូវធានាឱ្យបានសម្រេចតាមគោលដៅ និង

គោលការណ៍សំខាន់ៗ ក្នុងការផ្តល់សម្បទានដីសង្គមកិច្ចជូនដល់អតីតកងកម្លាំងប្រដាប់អាវុធ និង គ្រួសារដូចបាន គូសបញ្ជាក់ខាងលើ ។ លើសពីនេះទៀត នៅក្រោមសមត្ថកិច្ចដឹកនាំអនុវត្តរបស់យន្តការនេះ ការអនុវត្តការងារ សម្បទានដីសង្គមកិច្ចនៅតាមបណ្តាខេត្តមួយចំនួនធំ ដែលកំពុងតែដំណើរការទៅមុខប្រកបដោយលទ្ធផលផ្លែការ ល្អប្រសើរ ក៏នឹងត្រូវចូលរួមចំណែកផងដែរដល់ការធានានូវសង្គតិភាពខាងស្ថាប័ន និង សង្គតិភាពក្នុងការអនុវត្ត គោលនយោបាយរបស់រាជរដ្ឋាភិបាល

**ទី៧.** ក្នុងករណីចាំបាច់ គណៈកម្មាធិការសម្បទានដីសង្គមកិច្ចថ្នាក់ជាតិ អាចធ្វើការសម្របសម្រួល ជាមួយគណៈកម្មាធិការ និង ក្រសួង-ស្ថាប័នពាក់ព័ន្ធផ្សេងៗ ដើម្បីធានាប្រសិទ្ធភាពនៅក្នុងការអនុវត្តតាមភារកិច្ច នេះ ។

រាជរដ្ឋាភិបាលមានជំនឿយ៉ាងមុតមាំថា ប្រជាពលរដ្ឋទាំងអស់នឹងចូលរួមជាមួយក្រសួង ស្ថាប័នពាក់ ព័ន្ធទាំងអស់របស់រដ្ឋ ដើម្បីអនុវត្តគោលនយោបាយនេះ ឱ្យបានប្រសិទ្ធភាពខ្ពស់ ។

ភ្នំពេញ, ថ្ងៃទី ២៧ ខែ តុលា ឆ្នាំ ២០០៩

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**